# រដ្ឋាភិបាលនិងដៃគូជំរុញសកម្មភាពលើកកម្ពស់សុខភាពកុមារខ្វះអាហារូបត្ថម្ភ

**ឃួន លក្ខិណា**

**ភ្នំពេញៈ** មន្ត្រីរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា កុមារកម្ពុជាប្រមាណ៤០ភាគរយកំពុងជួបប្រទះនូវកង្វះអាហារូបត្ថម្ភ និងមិនទាន់ទទួលការថែទាំសុខភាពប្រកបដោយគុណភាពនៅឡើយ ហើយក៏បានអំពាវនាវឲ្យទាំងអស់គ្នា ពិសេសផ្នែកពាក់ព័ន្ធត្រូវប្រឹងប្រែងធ្វើឲ្យមានការផ្លាស់ប្តូរតាមរយៈ«យុទ្ធនាការលើកកម្ពស់សុខភាពកុមារឥឡូវនេះ»។

នៅក្នុងពិធីបើកសម្ពោធ«យុទ្ធនាការលើកកម្ពស់សុខភាពកុមារឥឡូវនេះ» ដែលប្រារព្ធជាលើកដំបូងនៅប្រទេសកម្ពុជា កាលពីព្រឹកថ្ងៃអង្គារ នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ លោកឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(CARD) បានថ្លែងថា ការបើកយុទ្ធនាការសុខភាពកុមារនាពេលឥឡូវនេះ គឺជាឱកាសមួយដែលតម្រូវឲ្យក្រសួងស្ថាប័ន អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងដៃគូអភិវឌ្ឍន៍ ហើយនិងអង្គការសង្គមស៊ីវិលត្រូវខិតខំធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។

លោកបន្តថា កង្វះអាហារូបត្ថម្ភមិនត្រឹមតែពាក់ព័ន្ធនឹងកំណើនអត្រាស្លាប់របស់កុមារទេ ប៉ុន្តែ បញ្ហានេះក៏ជះឥទ្ធិពលលើការអភិវឌ្ឍផ្នែកបញ្ញា ស្មារតី និងខួរក្បាលរបស់កុមារក៏ដូចជា កម្រិតអប់រំ ការអភិវឌ្ឍផ្នែករាងកាយនិងផលិតភាពរបស់កុមារផងដែរ។

លោក យឹម ឆៃលី គូសបញ្ជាក់ថាៈ «យើងដឹងថា មានកុមារជាច្រើននៅមិនទាន់បានទទួលការថែទាំសុខភាពប្រកបដោយគុណភាព មានឱកាសអប់រំរៀនសូត្រ និងបញ្ហាកសាងគ្រឹះនានា សម្រាប់អនាគតរបស់ពួកគេនៅឡើយទេ ដូច្នេះ នេះ ជាបញ្ហាដែលទាំងអស់គ្នាត្រូវចូលរួមដោះស្រាយ»។

ចាប់តាំងពីឆ្នាំ១៩៩០ អត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំ បានធ្លាក់ចុះរហូតដល់៦០ភាគរយ ប៉ុន្តែ បញ្ហាកង្វះអាហារូបត្ថម្ភកុមារហាក់មិនបានធ្លាក់ចុះតាមការចង់បានរបស់រដ្ឋាភិបាល និងបណ្តាអង្គការដៃគូឡើយ។ ហេតុដូច្នេះរដ្ឋាភិបាលនិងអង្គការដៃគូបានប្តេជ្ញាប្រឹងប្រែងប្រើប្រាស់គ្រប់កម្លាំង មធ្យោបាយ និងវិធានការរួមក្នុងការលើកកម្ពស់បញ្ហាអាហារូបត្ថម្ភសម្រាប់កុមារ ស្ត្រីមានផ្ទៃពោះនិងស្ត្រីក្នុងវ័យបន្តពូជ ដើម្បីសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា នៅក្នុងឆ្នាំ២០១៥។



**ស្ត្រីជាម្តាយនាំកូនៗដែលមានបញ្ហាមកពិនិត្យសុខភាពនៅមន្ទីរពេទ្យគន្ធបុប្ផា ភ្នំពេញ។** រូបថត ហុង មិនា

អ្នកស្រី កែវ មុំ អ្នកផលិតចំណីអាហារដែលមកចូលរួមពិធីនេះបានឲ្យដឹងថា កាលពី១១ឆ្នាំមុន អ្នកស្រីបានចាប់ផ្តើមចូលរួមចំណែកក្នុងការលើកកម្ពស់អាហារូបត្ថម្ភកុមារ តាមរយៈការផលិតចំណីអាហារ ដែលបានជួយផ្តល់ការងារដល់ប្រជាជនក្រីក្រកម្ពុជា និងអ្នកមិនចេះអក្សរ ឬអ្នកមានការចេះដឹងតិចតួច ជនពិការអសមត្ថភាពនិងកុមារកំព្រាឲ្យមានការងារធ្វើផងដែរ។ អ្នកស្រីបន្តថាៈ «យើងបានចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ និងផលិតអាហារសម្រន់សម្រាប់កុមារ ដែលមានគុណភាពខ្ពស់និងមានផ្ទុកសារជាតិចិញ្ចឹមជួយដល់កុមារផងដែរ»។

អ្នកស្រី ដួង ច័ន្ទធីតា ប្រធានគម្រោងយុទ្ធនាការលើកកម្ពស់សុខភាព នាយកដ្ឋានតស៊ូមតិនៃអង្គការទស្សនពិភពលោកកម្ពុជា ( World Vision )បានលើកឡើងថា កុមារជួបកង្វះអាហារូបត្ថម្ភ អាចបណ្តាលឲ្យកើតមានជំងឺស្គម ស្លេកស្លាំង ងាយនឹងកើតជំងឺជាច្រើន នៅក្នុងរយៈពេលខ្លី។ មិនតែប៉ុណ្ណោះ ពួកគេអាចប្រឈមទៅនឹងការចុះខ្សោយនៃកម្លាំងខួរក្បាល អាប់ប្រាជ្ញា ជាមនុស្សមិនសូវឆ្លាតវៃផងដែរ ក្នុងរយៈពេលវែង។ អ្នកស្រីបន្តថា ជាច្រើនឆ្នាំកន្លងមកនេះអង្គការទស្សនពិភពលោក ចាប់ផ្តើមគម្រោងការរបស់ខ្លួន នៅក្នុងខេត្ត-ក្រុងចំនួន៩ ផ្តោតទៅលើការផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋជាច្រើនគ្រួសារ បានយល់ដឹងអំពីប្រភេទអាហារូបត្ថម្ភ និងអត្ថប្រយោជន៍នៃការរស់នៅស្អាត និងការថែទាំ ការពារកុមារឲ្យមានសុខភាពល្អប្រសើរដើម្បីចៀសវាងនូវជំងឺផ្សេងៗទៀត។

ជាមួយគ្នាដែរ ដើម្បីប្រមូលនូវការផ្តល់អាទិភាព និងធ្វើសកម្មភាពដោះស្រាយរួមគ្នា លើបញ្ហាកង្វះអាហារូបត្ថម្ភកុមារនៅកម្ពុជា អង្គការទស្សនពិភពលោក បានរៀបចំយុទ្ធនាការតស៊ូមតិជាសាធារណៈមួយដែលអំពាវនាវឲ្យប្រជាជនកម្ពុជា យុវជន និងរដ្ឋាភិបាលត្រូវពិចារណាឡើងវិញទៅលើការលើកស្ទួយស្ថានភាពអាហារូបត្ថម្ភឲ្យបានកាន់តែប្រសើរឡើង៕ ■